00593544

D390/1

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 17 / 08 / 2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើជាបន្ទាន់របស់លោក អៀង សារី សុំអោយមានការបន្ថែមកម្រាស់ទំព័រ និង ពេលវេលាកំណត់ដើម្បីដាក់ចម្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានស្ថាពររបស់ កសព**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> | <u>ផ្ញើជូន៖</u> |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **សហចៅក្រមស៊ើបអង្កេត** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្ដម | ចៅក្រម យូ ប៊ុនឡេង | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម Marcel LEMONDE | លោក Andrew CAYLEY |
| | | |
| | | **ក្រុមមេធាវីការពារក្ដីទាំងអស់** |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification):
19-Aug-2010, 10:38
Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមស្នើសុំការបន្ថែមសេចក្តីកំណត់ជាធរមានអំពីកម្រាស់ទំព័រត្រឹមកម្រិត ១៥ ទំព័រ[1] និងកាលកំណត់បរិច្ឆេទដាក់ឯកសារត្រឹមកំរិត ១៥ថ្ងៃ[2] ដើម្បីដាក់ចម្លើយតបទៅនឹង សេចក្តីសន្និដ្ឋានស្ថាពររបស់ការិយាល័យសហព្រះរាជអាជ្ញា (“កសព”)[3] ។ មេធាវីការពារក្តីមិនទាន់បានទទួលជាផ្លូវការនៅឡើយទេនូវការដាក់ឯកសារសេចក្តីសន្និដ្ឋានស្ថាពរនេះ ប៉ុន្តែបានទទួលសេចក្តីប្រកាសព័ត៌មានរបស់ កសព ដែលថ្លែងថា សេចក្តីសន្និដ្ឋានស្ថាពរបានដាក់រួចហើយកាលពីថ្ងៃទី ១៦ សីហា ២០១០ ហើយវាមានកម្រាស់ ៨៣១ ទំព័រ[4]។ រឿងនេះមិនអាចធ្វើទៅបានឡើយសម្រាប់ការឆ្លើយតប អោយអស់សេចក្តីទៅនឹងសេចក្តីសន្និដ្ឋានស្ថាពរដែលមានកម្រាស់ ៨៣១ ទំព័រ ត្រឹមការឆ្លើយតបដែលមានកម្រាស់ត្រឹម ១៥ ទំព័រនោះ។ ករណីនេះក៏រឹតតែមិនធ្វើទៅបានទៀត ក្នុងការអាន សេចក្តីទៅនឹងសេចក្តីសន្និដ្ឋានស្ថាពរដែលមានកម្រាស់ ៨៣១ ទំព័រ ព្រមទាំងធ្វើការវិភាគវាយតម្លៃ និងព្រាងតាក់តែងសេចក្តីឆ្លើយតប ហើយធ្វើការបកប្រែសេចក្តីឆ្លើយតបនៅក្នុងរយៈពេលត្រឹមតែ ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីការដាក់ឯកសារ។ យោងទៅតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅចំពោះមុខ អវតក កសចស អាចបន្ថែមពេលកម្រាស់ទំព័រកំណត់ ១៥ ទំព័រនេះបាននៅក្នុងកាលៈទេសៈពិសេសមួយចំនួន។ យោងទៅតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងរបស់ អវតក កសចស អាចបន្ថែមពេលវេលាកំណត់ទៅតាមសំណើសុំរបស់គូភាគីបាន។ ដោយអនុលោមទៅតាមកាតព្វកិច្ចវីរិយភាព[5] (Due Diligence) ដែលសហមេធាវីការពារក្តីត្រូវគោរពតាម ការឆ្លើយតបអោយ

---

[1] មាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក ចែងថា “ឯកសារដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ របស់ អវតក មិនត្រូវមានកម្រាស់លើសពី ១៥ទំព័រជាភាសាអង់គ្លេស ...”។

[2] មាត្រា ៨.៣ នៃ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក ចែងថា “ការឆ្លើយទៅនឹងសារណានានាត្រូវដាក់ធ្វើឡើងជាមួយនឹងបញ្ជីឯកសារយោងនៅក្នុងរយៈពេល ១៥ ថ្ងៃនៃប្រក្រតីទិនគិតពីថ្ងៃទទួលការជូនដំណឹងនៃការដាក់ឯកសារ ...”។

[3] គួរកត់សម្គាល់ថា នៅក្នុងរឿងក្តី ០០១ មេធាវីការពារក្តី ឌុច ត្រូវបានអនុញ្ញាតអោយដាក់ការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ថាពរ។ *សូមមើល រឿងក្តី កាំងហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១-១៨-០៧-២០០៨-អវតក/កសចស សារណាការពាររបស់មេធាវីការពារក្តី ចុះថ្ងៃទី ២៤ កក្កដា ២០០៨ ឯកសារលេខ D96/1, ERN: 00224323-00224332 ។ *សូមមើល រឿងក្តី កាំងហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១-១៨-០៧-២០០៨-អវតក/កសចស ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំងហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ៨ សីហា ២០០៨ ឯកសារលេខ D99 កថាខណ្ឌ ៨ ។

[4] សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ សីហា ២០១០។

[5] កាតព្វកិច្ចនេះដាក់បន្ទុកដល់មេធាវីការពារក្តី អោយបំពេញកិច្ចប្រកបដោយវីរិយភាព ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់លោក អៀង សារី

បានពេញលេញអស់សេចក្តី មិនអាចដាក់ជូននៅក្នុងកម្រិត ១៥ទំព័រ ហើយក្នុងរយៈពេល ១៥ ថ្ងៃកំណត់នេះបានឡើយ។

**អាស្រ័យហេតុនេះ** យោងតាមហេតុដូចមានចែងខាងលើ មេធាវីការពារក្តីសូមស្នើដោយក្តីគោរព ដល់សហចៅក្រមស៊ើបអង្កេត សូមបន្ថែមកម្រាស់ទំព័រកំណត់រហូតដល់ ៧០ទំព័រ ហើយបន្ថែមពេលវេលាកំណត់ចំនួន ១៥ថ្ងៃទៀត។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១០

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

---

ហើយដូច្នេះ មេធាវីការពារក្តីបំពេញកាតព្វកិច្ចនេះដើម្បីធានាថា ការជំនុំជម្រះក្តីរបស់គាត់មានភាពយុត្តិធម៌។ ការពិភាក្សាអំពីភាពចាំបាច់អោយមានវិរិយភាពទាក់ទងទៅនឹងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំកិច្ចការពារក្តី អ្នកសិក្សាជាន់ខ្ពស់ម្នាក់បានកត់សម្គាល់ថា “ទាក់ទងទៅនឹងទាំងពេលវេលា និងមធ្យោបាយ គេរំពឹងថាមាន ហើយមានភាពចាំបាច់ត្រូវមានវិរិយភាពក្នុងកម្រិតមួយចំនួនធ្លាក់មកលើមេធាវីការពារក្តី។ <u>មេធាវីការពារក្តី អាចត្រាន់តែតវ៉ាអំពីការរំលោភបំពាននូវសិទ្ធិរបស់ពួកគេ បើសិនគេបានធ្វើអ្វីដែលចាំបាច់</u> តាមច្បាប់ជាតិដើម្បីទទួលបាន(ការបន្ថែម)ពេលវេលា និងមធ្យោបាយសមស្រប” ។ STEPHAN TRECHSEL, HUMAN RIGHTS IN CRIMINAL PROCEEDINGS 214 (Oxford University Press, 2005) (គូសបញ្ជាក់បន្ថែម)។